**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៧០១.....សហវ.ប្រក

# ប្រកាស
## ស្តីពីការដកហូតអាជ្ញាប័ណ្ណអាជីវកម្មស្លុតម៉ាស៊ីន
## របស់ក្រុមហ៊ុន VINA HONG KONG CO., LTD

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសារាចរលេខ ០៦ សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) របស់រាជរដ្ឋាភិបាល
- បានឃើញលិខិតលេខ ៣០៤ សជណ ចុះថ្ងៃទី២២ ខែ មីនា ឆ្នាំ២០០៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន VINA HONG KONG CO., LTD ធ្វើអាជីវកម្មល្បែងកំសាន្តស្លុតម៉ាស៊ីន
- បានឃើញអាជ្ញាប័ណ្ណស្លុតម៉ាស៊ីន លេខ ១៣២ សហវ.ឧហ របស់ក្រុមហ៊ុន VINA HONG KONG CO., LTD ដែលផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ២៤៧ សហវ.ប្រក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រង់ប្រការ ១១ ស្តីពីការដកហូតអាជ្ញាប័ណ្ណ ។
- សៀវភៅបន្ទុកលេខ ០២១ សហវ.ឧហ ចុះថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រង់ប្រការ៤ ស្តីពីការដកហូតអាជ្ញាប័ណ្ណ ។
- ការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០០៩ ក្នុងពិធីចែកសញ្ញាប័ត្រដល់និស្សិតនៅវិទ្យាស្ថានជាតិអប់រំ នៅរាជធានីភ្នំពេញ
- លិខិតលេខ៦៦លស.ក្រ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់សាលាក្រុងភ្នំពេញ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

# ស ម្រេ ច

**ប្រការ ១ :** ដកហូតអាជ្ញាប័ណ្ណអាជីវកម្មស្លុតម៉ាស៊ីនលេខ ១៣២ សហវ.ឧហ របស់ក្រុមហ៊ុន VINA HONG KONG CO., LTD ដោយមូលហេតុ ក្រុមហ៊ុនពុំបានអនុវត្តតាមសេចក្តីណែនាំ ស្តីពីលក្ខខណ្ឌអនុវត្តអាជ្ញាប័ណ្ណស្លុត-ម៉ាស៊ីនត្រង់ប្រការ៤ និង ប្រកាសលេខ ២៤៧ សហវ.ប្រក ត្រង់ប្រការ១១ ស្តីពីការដកហូតអាជ្ញាប័ណ្ណ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៦សរណន ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨។

**ប្រការ ២ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ក្នុង ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- សាលាក្រុងភ្នំពេញ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ២ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ